# ព្រះរាជក្រឹត្យ

នស/រកត/០៥០០/០៩៦

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល

## ក្រសួងមហាផ្ទៃ

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **គ** ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ មានមុខងារក្នុងលេខាធិការដ្ឋាន និងមុខងារប្រតិបត្តិនៅអង្គភាពរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង។

## ជំពូកទី ២

## ឋានន្តរសក្តិ ថ្នាក់ និង មុខតំណែងក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃមាន ៣ ឋានន្តរសក្តិ ៖

- នាយលេខាធិការរដ្ឋបាល : មាន ០៦ ថ្នាក់
- លេខាធិការរដ្ឋបាលដើមខ្សែ : មាន ១០ ថ្នាក់
- លេខាធិការរដ្ឋបាល : មាន ១៤ ថ្នាក់។

**មាត្រា ៥.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ក្រសួងមហាផ្ទៃនេះ មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងជា ៖

- អនុប្រធានការិយាល័យ នៅសាលាស្រុក ខ័ណ្ឌ
- ស្មៀនឃុំ សង្កាត់

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី ៣

## ការជ្រើសរើស និង ការបណ្តុះបណ្តាលដំបូង

**មាត្រា ៦.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ឬ និង ក្នុងចំណោមសិស្ស និស្សិត។ ចំនួននៃតំណែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែងសំរាប់មន្ត្រីរាជការ និង សិស្ស និស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុត

សមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ និង មានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខណ្ឌប្រភេទ **ឃ** និងមានអាយុយ៉ាងច្រើនបំផុត ៤០ ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី២ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌឋានន្តរសក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤០ ឆ្នាំ ។

**មាត្រា ៨.-**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងក្នុងចំណោមសិស្ស និស្សិត មានឋានៈជាសិស្សមន្ត្រីលេខាធិការរដ្ឋបាល ហើយការបណ្តុះបណ្តាលដំបូង ត្រូវរៀបចំឡើងដោយក្រសួងមហាផ្ទៃ។

# ជំពូកទី ៤

## កម្មសិក្សា និង ការតាំងស៊ប់

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានចាត់អោយទៅបំរើការងារតាមអង្គភាពនានា ក្រោមឱវាទក្រសួងមហាផ្ទៃ ហើយត្រូវបានតែងតាំងជាមន្ត្រីលេខាធិការរដ្ឋបាលកម្មសិក្សា ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

មន្ត្រីកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយ ដែលមានរយៈពេលដូចខាងក្រោម ៖

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិត ។

២- ០៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី១ និង ទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាល។ ក្នុងករណីចាំបាច់ អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង ០៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោលប្រសិនចេញមកពីសិស្ស និស្សិត ឬមួយបញ្ចូលទៅក្របខ័ណ្ឌដើមវិញប្រសិនចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាពការងារ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសំណើរបស់អង្គភាពសាមី ដោយបញ្ជាក់នូវមូលហេតុ ធ្វើឡើងរយៈពេលយ៉ាងយូរ ០៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា។

មន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន។

មន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់ លេខ ១៤ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាល។

ការតែងតាំងស៊ប់ក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាល នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃរួចហើយ មន្ត្រីលេខាធិការរដ្ឋបាលទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- មានស្មារតីទទួលខុសត្រូវ
- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ
- មានសីលធម៌ល្អ។

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

**មាត្រា ១២.-**

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរ នៅក្នុងឋានន្តរសក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរសក្តិ ឬតាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍ភាគរយ ៖

- ៥ ភាគរយ ចំពោះឋានន្តរសក្តិនាយលេខាធិការរដ្ឋបាល
- ២៥ ភាគរយ ចំពោះឋានន្តរសក្តិលេខាធិការរដ្ឋបាលដើមខ្សែ
- ៧០ ភាគរយ ចំពោះឋានន្តរសក្តិលេខាធិការរដ្ឋបាល។

ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១៣.-**

អាចតម្លើងទៅក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាល ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយលេខាធិការរដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាលដើមខ្សែ ។

**មាត្រា ១៤.-**

សន្ទស្សន៍សម្រាប់ថ្នាក់ ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ និងតម្លៃឯកតានៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២ បូកពីរឆ្នាំសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ១៦.-**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវដាក់ឱ្យចូលនិវត្តន៍នៅពេលដល់អាយុ ៥៥ ឆ្នាំ ។ ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ចំនួនដំបូងនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និង មុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២០.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខៈ ៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ណាឌី តាន់**